# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ថ្ងៃ ចន្ទ ១១រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២៥

លេខ :០៦៩៤.កឃរ.សរទ/២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានី-ខេត្ត**

**កម្មវត្ថុ ៖** សំណើសុំបញ្ជូននូវរាល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងការលក់ដោយបង្ខំនូវអចលនវត្ថុតាមផ្លូវតុលាការ ក្នុងទម្រង់ជាឯកសារអេឡិចត្រូនិច (Soft Copy) ជូនមកក្រសួងយុត្តិធម៌ ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមប្រធានសាលាដំបូង** ជ្រាបថា ក្នុងគោលបំណងជំរុញការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ដោយបង្ខំនូវអចលនវត្ថុតាមផ្លូវតុលាការ ដែលធ្វើឡើងនៅតាមសាលាដំបូងរាជធានី-ខេត្តឱ្យបានកាន់តែទូលំទូលាយ សំដៅចូលរួមលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុតាមផ្លូវតុលាការ ក្រសួងយុត្តិធម៌នឹងធ្វើការផ្សព្វផ្សាយនូវព័ត៌មានពាក់ព័ន្ធនឹងការលក់ដោយបង្ខំនូវអចលនវត្ថុតាមផ្លូវតុលាការ នៅលើបណ្តាញផ្សព្វផ្សាយព័ត៌មានផ្លូវការរបស់ក្រសួងយុត្តិធម៌ បន្ថែមលើយន្តការផ្សព្វផ្សាយរបស់សាលាដំបូងរាជធានី-ខេត្ត ដែលបានអនុវត្តកន្លងមក។

ក្នុងន័យនេះ ដើម្បីអនុវត្តកិច្ចការនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងយុត្តិធម៌ស្នើសុំឱ្យសាលាដំបូងរាជធានី-ខេត្តទាំងអស់ ត្រូវបញ្ជូនរាល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងការលក់ដោយបង្ខំ ក្នុងទម្រង់ជាឯកសារអេឡិចត្រូនិច (Soft Copy) រួមមាន ឯកសារលម្អិតអំពីអចលនវត្ថុ, ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា, ដីកាសម្រេចបង្គាប់ឱ្យអនុវត្តការលក់, ការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ ព្រមទាំងរូបថត និងទីតាំងនៃអចលនវត្ថុ ជូនមកក្រសួងយុត្តិធម៌ ឱ្យបានយ៉ាងតិច **៣ (បី) សប្តាហ៍** មុនកាលបរិច្ឆេទកំណត់នៃការអនុវត្តការលក់ដោយបង្ខំ ដើម្បីក្រសួងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

សម្រាប់ការទំនាក់ទំនងក្នុងការបញ្ជូនព័ត៌មាន និងឯកសារពាក់ព័ន្ធខាងលើ សូមធ្វើការទាក់ទងមកនាយកដ្ឋានកិច្ចការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី តាមរយៈលេខទូរសព្ទ **០១១ ៧៣៨ ៥៨៥ / ០៦៩ ៨៥៨ ០០៥**។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធានសាលាដំបូង** ពិនិត្យ និងចាត់ចែងអនុវត្តតាមការគួរ។

សូម **ឯកឧត្តមប្រធានសាលាដំបូងរាជធានី-ខេត្ត** ទទួលការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ



Khmer Law Association, www.khmerlaw.org